## ៧. ការពិគ្រោះយោបល់សាធារណៈ

**២៣២.** ការពិគ្រោះយោបល់សាធារណៈ ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ ភូមិ និងប្រជាជន សហគមន៍ដែលពាក់ព័ន្ធបានរៀបចំធ្វើឡើងនៅក្នុងដំណើរការរៀបចំរបាយការណ៍ ដើម្បីធ្វើការព្យាករណ៍អំពីហេតុប៉ះពាល់ និងផ្តល់នូវអនុសាសន៍ជាមូលដ្ឋាន។ សមាសភាពដែលបានចូលរួមពិគ្រោះយោបល់មាន : ឯកឧត្តមអភិបាលរងខេត្តកំពង់ធំ នាយករដ្ឋបាលសាលាខេត្ត នាយរងទីចាត់ការអន្តរវិស័យ អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ អនុប្រធានមន្ទីរដែនដីនគររូបនីយកម្ម និងសំណង់ នាយផ្នែករដ្ឋបាលព្រៃឈើខេត្តកំពង់ធំ អភិបាលរងស្រុកសន្ទុក មន្ត្រីការិយាល័យផែនការ នៃមន្ទីរកសិកម្មខេត្ត អនុការិយាល័យ កសិកម្ម នៃមន្ទីរកសិកម្មខេត្ត សរុបចំនួន០៩នាក់ កាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១១ នៅសាលាខេត្ត កំពង់ធំ។(ឧបសម្ព័ន្ធ៧: **តារាង៧-១**) របាយការណ៍ កំណត់ហេតុពិគ្រោះយោបល់មានក្នុងឧបសម្ពន្ធ័ ៨ និងរូបភាពប្រជុំមាននៅក្នុង **ឧបសម្ព័ន្ធ ៧-៣**។ ក្រុមការងាររបស់ GCF ក៏បានចុះទៅដល់មូលដ្ឋាន ដើម្បីធ្វើការពិភាក្សា និងពិគ្រោះ យោបល់ជាមួយមេឃុំ និងលោកអភិបាលស្រុកសន្ទុក មេឃុំក្រយា ស្មៀនឃុំក្រយា សរុបចំនួន ៣នាក់ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១១ (**ឧបសម្ព័ន្ធ៧ : តារាង៧-២** និង រូបភាពនៅក្នុង **ឧបសម្ព័ន្ធ៧-៣**) ។

**របាយការណ៍សង្ខេប ស្តីពីការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានលើការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**

**២៣៣.** ក្នុងឱកាសចូលរួមពិគ្រោះយោបល់ តំណាងថ្នាក់ដឹកនាំមូលដ្ឋាន ខេត្ត ស្រុក មន្ទីរជំនាញ និងប្រជាជនក្នុងសហគមន៍ ទាំងមូល បានមានមតិ និងសំណូមពរដូចខាងក្រោម:

- **ឯកឧត្តម អ៊ុក សំអន អភិបាលរងខេត្ត កំពង់ធំ** : លោកមានប្រសាសន៍ថា ទីមួយការចូលទៅធ្វើការកាប់ រានរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់។ ទី២ គួរជាការចូលរួមកាប់បំផ្លាញពីសំណាក់មន្ត្រី ឬប្រជាពលរដ្ឋដែលមានមុខការ នៅកន្លែងនោះផងដែរ អាចមានកងកំលាំងប្រដាប់អាវុធក៏មានដែរ។ ទី៣ ដូចជាកន្លែងខ្លះក្រុមហ៊ុនខ្លួន ឯងបានឈូសជ្រុល ឧទាហរណ៍ច្បាប់កំណត់ថាទុក១០០ម៉ែត្រ តែក្រុមហ៊ុនឈូសជ្រុលរហូតដល់មាត់ច្រាំង ហើយនៅកន្លែងខ្លះមានឈូសឈើហើយតែអត់ដាំក៏មានដែរ នេះខ្ញុំកត់សំគាល់ឃើញប៉ុណ្ណេះ តែចំណុចល្អឃើញថា ក្រុមហ៊ុនក្រោយពីបាន (សជណ)ហើយក្រុមហ៊ុនចាប់ផ្តើមមានសកម្មភាពឈូសឆាយដាំមែន។ ក្រុមហ៊ុនមិនមានអនុភាពខាងផ្លូវច្បាប់ ឬក៏ឥទ្ធិពលអវិជ្ជមានធ្វើ អោយប្រជាពលរដ្ឋចេះតែចូលទៅកាប់រាន អញ្ចឹងគឺករណីនេះគឺយើងសំគាល់ឃើញផងដែរការងារនេះនៅពេល ដែលត្រឡប់ទៅរកវិធានការសារជាថ្មីវិញគឺថាក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ឧទាហរណ៍ថា ពាក់ព័ន្ធជាមួយ និងប្រជាពលរដ្ឋក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរ តើត្រូវដេញ ឬក៏ចាត់វិធានការ នៅទីនោះផ្ទាល់តែម្តងតែបើពាក់ព័ន្ធអ្នកដែលនៅ

ក្រុមហ៊ុននេះផ្ទាល់ហើយស្ទាត់ច្រៀបមិន ឃើញធ្វើអីសោះ នោះ ក្រុមហ៊ុនត្រូវសហការជាមួយជំនាញពិនិត្យឡើងវិញនូវអ្វីដែលបានប៉ះពាល់រួចទៅហើយគួរប៉ះប៉ូវឡើង វិញតាមរបៀបយ៉ាងម៉េច?ដូចនេះសុំឱ្យជំនាញរៀបចំរបាយការណ៍ឡើងទៅសាមីក្រសួងផ្ទាល់ ដើម្បីមានវិធានការផ្លូវច្បាប់នេះគឺខ្ញុំចាប់អារម្មណ៍ផ្ទាល់នូវអ្វីដែលខ្ញុំបានតាមដាននឹងឃើញផ្ទាល់ ហើយចំពោះអ្វីដែល បានលើកឡើងនេះគឺវាត្រឹមត្រូវទេ ហើយបើមានអ្វីជាផ្សេងទៀតសូមលើកជាអនុសាសន៍មក ។

ក្នុងការធ្វើបទបង្ហាញនៅពេលនេះ តើខាងក្រុមការងារ EIA ចង់បាន អនុសាសន៍ក្នុងការឱ្យមានការប៉ះប៉ូវពីក្រុមហ៊ុនមកវិញឬយ៉ាងម៉េច ចំពោះក្រុមហ៊ុនដែលបានធ្វើការឈូសលើសផ្ទៃដីដែលបានកំណត់នេះ ដែលជាធម្មតាការងារនេះមានក្រសួងពីរដែលទទួលខុសត្រូវ ក្នុងនោះមានក្រសួងកសិកម្ម ដែលមានរដ្ឋបាលព្រៃឈើជាសេនាធិការផ្ទាល់ ហើយក្រសួងបរិស្ថានអ្នកតាមដានវាយតំលៃហេតុ ប៉ះពាល់បរិស្ថាន បើករណីក្រុមហ៊ុនមិនគោរពនូវគោលការរបស់ក្រសួងណាមួយនោះក្រុមហ៊ុនជាអ្នកទទួល ដោះស្រាយជាមួយផ្លូវច្បាប់ទាំងនោះដូចយើងដឹងហើយករណីក្រុមហ៊ុន **តាន បៀន** នេះនៅម្តុំភ្នំប្រាច់ ឃើញថា ព្រៃរក្សាទុកនៅក្នុងក្រុមហ៊ុនគឺត្រូវបានប្រជាជនចូលកាប់រានឬខាងណាក៏មិនដឹង តែជាក់ស្តែងព្រៃ នោះត្រូវរុករានស្ទើរអស់ហើយដែរ ដូចនេះតើយើងគួលើកវិធានការយ៉ាងម៉េចចំពោះអ្វី ដែលនៅមានសេស សល់ទាំងនោះកុំឱ្យបន្តបាត់បង់បន្ថែមទៀត ។ ទី១ត្រូវស្គាល់ទីតាំង ដែលយើងត្រូវទទួលខុសត្រូវឱ្យបានច្បាស់លាស់ ។ ទី២យើងត្រូវសិក្សាឡើងវិញថាតើព្រៃនោះទទួលរងការ បំផ្លេចបំផ្លាញដូចម្តេច? ដោយកំណត់ឱ្យច្បាស់ថាចលករគឺជាអ្នកណា? បើប្រជាពលរដ្ឋយើងត្រូវសហការជា មួយអាជ្ញាធរ ទើបអាចដឹងថាប្រជាពលរដ្ឋទាំងនោះចេញមកពីណាដែលអាជ្ញាធរ មានសមត្ថកិច្ចត្រូវធ្វើការគៀងគរប្រជាពលរដ្ឋរបស់ខ្លួនទាំងនោះ ឱ្យត្រឡប់ទៅភូមិរបស់គាត់វិញ ។ ទី៣ក្នុងករណី យើងទទួលបានថា ក្រុមហ៊ុនមិនបានអនុវត្តន៍ឱ្យបានត្រឹមត្រូវតាម (ស.ជ.ណ) របស់រាជរដ្ឋាភិបាល ឈូសឆាយប៉ះពាល់ដល់ព្រៃដែលបានរក្សាទុកជាប្រយោជន៍នោះ អាជ្ញាធរត្រូវជូនដំណឹងជំរាបទៅរកក្រុមហ៊ុនឱ្យបញ្ឈប់ការឈូសចូលទៅមុខទៀត ដូចនេះយើងត្រូវសិក្សាថាតើត្រូវដាំឡើងវិញឬក៏យ៉ាងម៉េច? ដែលតំរូវឱ្យយើងចុះសិក្សាឡើវិញ ផងដែរ ។

- **លោក អោង ប៊ុនធឿន** អនុប្រធានមន្ទីរបរិស្ថានខេត្ត : ចំពោះការវាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ក្រុមហ៊ុនប្រាកដជាបានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលរួចហើយ នៅក្នុងកិច្ចការពារបរិស្ថាននោះ ដូចជាថា ការការពារព្រៃដែលត្រូវរក្សាទុកនៅតំបន់ការការការហូច្រោះ ផ្ទៃដីព្រៃបំរុងទុកអ្វីជាដើមនោះ ដោយករណីការឈូសហួសរបស់ក្រុមហ៊ុនជាដើម ។ តែដោយឡែកការធ្វើបទបង្ហាញស្តីពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់និស្ថាននេះមិនបានសរសេរ លំអិតអំពីហេបុះពាល់



Draft

បរិស្ថាន និងវិធានការកាត់បន្ថយនោះទេ ដូចនេះសុំក្រុមហ៊ុនធ្វើការសេរសេរឱ្យបានច្បាស់ត្រូវតែគិត ព្រោះកន្លងមកក្រុមហ៊ុនបានធ្វើឱ្យប៉ះពាល់ដល់ បរិស្ថានរួចមកហើយដូចនេះតើមានវិធានការយ៉ាងណា ទៀតនៅពេលអនាគតដែលវានឹងអាចមានផលប៉ះពាល់តទៅទៀតនោះ។ ដូចនេះ ហើយខ្ញុំសូមសំណូមពរឱ្យសុំអោយបញ្ចូលឱ្យបានច្រើនក្នុងការកាត់បន្ថយការប៉ះពាល់បរិស្ថាន និងការ បំពុលទឹកជាដើម។ នៅក្នុងរបាយការណ៍យើងឃើញមាន ការទាក់ទងនឹងសត្វព្រៃ នៅពេលដែលមានការឈូសឆាយព្រៃឈើទៅវាទាក់ទងនឹងការបំលាស់ទីនៃការ បំលាស់ទីរបស់សត្វព្រៃ តើចំពោះការវាយតំលៃផលវិជ្ជមាននៅពេលដែលព្រៃកៅស៊ូមានការស្តារឡើងវិញ តើសត្វព្រៃមានការប្រែប្រួលត្រឡប់ឡើងវិញ ឬអាចកកើតនៅក្នុងនោះបានដែរ ឬយ៉ាងណា ?

- **លោក ហុង សេងហាក់** មន្ត្រីការិយាល័យផែនការកសិកម្មខេត្ត : ខ្ញុំមានយោបល់មួយចំនួនទាក់ទងទៅនឹង ការសិក្សាវាយតំលៃ ដែលនៅក្នុងសេចក្តីសន្និដ្ឋានអត់បានពិនិត្យឃើញ ថាតើក្រោយពីការឈូសឆាយព្រៃនេះទៅ ហើយជំនួសដោយព្រៃកៅស៊ូវិញ តើមានការកាត់បន្ថយការប៉ះពាល់ទៅលើគំរប់ព្រៃឈើដែរឬទេ ? ហើយ បើមានការប៉ះពាល់ តើរយៈពេលប៉ុន្មានដែលអាចស្តារឡើងវិញនៅផលប៉ះពាល់ទាំងនោះ ? តើក្រុមហ៊ុន មានបានធ្វើការប្រៀបធៀបទេ? ជាការពិត យើងឃើញថាក្រុមហ៊ុនទាំងបីនេះ បានឈូសឆាយនិងដាំ ស្ទើរទាំងអស់ទៅហើយបើតាមរបាយការណ៍គឺ នៅសល់ផ្ទៃដីមិនដល់ ២០០០ ហិកតាទេនេះជាចំណុចទី១ ហើយចំណុចទី២ និយាយអំពីចំណុចប៉ះពាល់បរិស្ថានដែលយើងមើលឃើញសព្វថ្ងៃនេះគឺ មានផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ហើយផលប៉ះពាល់សង្គមនេះ គឺយើងបានជួបប្រទះហើយនឹងបានធ្វើការដោះស្រាយជាបន្តបន្ទាប់ដោយឡែកចំពោះផលប៉ះពាល់បរិស្ថាន យើងគិតថា មិនទាន់ឃើញថាការវាយតំលៃនេះ រៀបរាប់ផលប្រយោជន៍យ៉ាងណានោះទេ ផ្តោតទៅលើការបំរែបំរួលអាកាសធាតុ ដែលយើងឃើញថា វាក្តៅហើយភ្លៀងនេះជាចំណុចមួយនៃការវាយតំលៃផលប៉ះពាល់បរិស្ថាន ហើយចំណុចទី២ គឺការឈូសខុសការគំណត់ខុសនិយាមកាដែលកំណត់នៅក្នុងផែនការមេ និង កិច្ចសន្យា អញ្ចឹងជាយោបល់របស់ខ្ញុំ យើងអាចចាត់ទុកថាជាអនុសាសន៍នោះគួរតែឱ្យមានសិក្សាលំអិតនៅ ចំណុចដែលក្រុមហ៊ុនបានអនុវត្តន៍ ដោយជាក់ស្តែង ហើយប្រៀបធៀបនិយាមកាដែលមានចែងនៅក្នុងកិច្ចសន្យា និងផែនការមេនេះគឺជាចំណុចទី១។ ក្នុងចំណុចទី២ ដូចប្រសាសន៍លោកអនុប្រធានមន្ទីប្រធានបរិស្ថាន សូមលោកនាយកអាចសរសេរអោយបានលំអិតនៅរបាយការណ៍ដែលយើងបានឃើញជាក់ស្តែងនូវចំណុចដែលខុសពីផែនការមេ យើងសរសេរនេះមានន័យថា យើងមិនមែនមានបំណងធ្វើបាបក្រុមហ៊ុនដែលបានអនុវត្តន៍ខុសទេ ប៉ុន្តែនេះចាត់ ទុកថាជាមេរៀនសិក្សា ឬជាបទពិសោធន៍មួយសំរាប់ក្រុមហ៊ុនក្រោយៗទៀត ហើយមានន័យថាគួរតែ មានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននិងការអនុញ្ញាត ឱ្យធ្វើសម្បទាន

Draft

វិនិយោគ។ នៅក្នុងរបាយការណ៍ដែលបានធ្វើបទ បង្ហាញនេះ ឃើញថាក្រុមហ៊ុនបានធ្វើការឈូសឆាយដាំដុះស្ទើរតែរួចអស់ទៅហើយ ប៉ុន្តែនៅក្នុងនេះ យើងគិត ថាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន យើងគួតែរំលេចនៅចំណុចណាមួយដែលយើងបានបញ្ជាក់ថា មិនបានធ្វើការវាយតំលៃទៅលើសកម្មភាព ជាក់ស្តែងរបស់ក្រុមហ៊ុនត្រង់ចំណុចនេះខ្ញុំចង់បញ្ជាក់ថាដោយក្នុងរបាយការណ៍នេះសរសេរថា ជារបាយការណ៍ដំបូង ដូចនេះចង់បានឱ្យក្រុមហ៊ុនកុងស៊ុលតង់សរសេរចងត្រង់ណាមួយដើម្បីឱ្យដឹងថារបាយការណ៍នេះនៅមានសល់ចំណុចនានាដែលយើងមិនទាន់បានធ្វើ ?

- **លោក សុទ្ធ ម៉ារី** នាយផ្នែករដ្ឋបាលព្រៃឈើកំពង់ធំ :អំពីការកាប់រានទៅតំបន់ព្រៃរក្សាទុក ហើយខាងខ្ញុំក៏ទទួលបាននៅការបញ្ជាផ្ទាល់តាមរយៈឯកឧត្តមរដ្ឋមន្ត្រីពី របាយការណ៍ កាប់រានព្រៃនៅតំបន់ភ្នំប្រាច់នេះ ដែលរងនូវសកម្មភាពធ្ងន់ធ្ងរ ហើយខាងរដ្ឋបាលព្រៃយើងខ្ញុំនេះ មិនមែនមិនមានការចាប់អារម្មណ៍ មិនអើពើរនោះទេ ដោយមានសំណើរពីក្រុមហ៊ុនមករដ្ឋបាលព្រៃឈើយើងដែរក្នុងការសហការណ៍រកវិធានការដោះស្រាយ ហើយទិដ្ឋភាពការងារសព្វថ្ងៃនេះ ហាក់ដូចជាមិនទាន់មានការចូលរួមពេញលេញពីភាគីក្រុមហ៊ុននៅឡើយនោះទេ គឺថាការងារធ្វើដោយឡែក១ពីគ្នា ករណីនេះគឺចង់ សំដៅទៅលើការចុះអនុវត្តន៏ការងារ ដែលស្តែងចេញពីបញ្ហាថវិកាតែម្តង។ ក្នុងការចុះអនុវត្តការងារដែល កន្លងមកយើងទាមទារឱ្យខាងក្រុមហ៊ុនចូលរួម ដើម្បីមានលទ្ធភាពផ្តល់នូវអ្វីដែលជាសេវាគាំទ្រ (ថវិកា) ក្នុងការងាររួមសហការណ៍គ្នា ប៉ុន្តែលទ្ធផលនោះពេលយើងដាក់សំណើទៅឃើញថាមានផលវិជ្ជមានតិចតួច ឆ្លៀតឱកាសថ្ងៃនេះ តាំងនាមឱ្យខ័ណ្ឌរដ្ឋបាលព្រៃឈើសំណូមពរដល់ឯកឧត្តមប្រធានអង្គប្រជុំ ថាការងារនេះ ជាទូទៅត្រូវតែ បើកទំព័រការងារជាប្រវត្តិសាស្ត្រការងារមួយនៅលើក្រុមហ៊ុនទាំងបីនេះ ដូចខាងមន្ទីរកសិកម្ម លើកឡើងហើយដើម្បីបានជាគំរូមួយទៅដល់ក្រុមហ៊ុនក្រោយ១ ដូចនេះយើងគួធ្វើការងារឱ្យមានលក្ខណៈ លំអិតដោយឡែកលើកនូវអ្វីដែលកំពុងតែមានសកម្មភាព ដូចជាករណីដីដែលឈូសឆាយដាំកៅស៊ូរួចអស់ ហើយយើងគួរតែជំរុញបញ្ចេញរបាយការណ៍ទៅ ឱ្យថ្នាក់ដឹកនាំខាងលើបានជ្រាបបានហើយដើម្បីបញ្ចប់បញ្ហា នេះ។

**២៣៤.** ក្នុងឱកាសចូលរួមពិគ្រោះយោបល់ បងប្អូនតំណាងអោយប្រជាជនក្នុងសហគមន៏ទាំងមូល បានមានមតិ និងសំណូមពរដូចខាងក្រោម :

- លោក **ពេជ សុធា** អភិបាលស្រុកសន្ទុក : តាមតែខ្ញុំធ្លាប់ដឹងនឹងចុះទៅផ្ទាល់ជាមួយក្រុមការងារ អន្តរក្រសួង កាលពីនៅសាលាខេត្ត មុននឹងបានមកធ្វើឈរជើងជាអភិបាលស្រុកនៅទីនេះ ចំពោះក្រុមហ៊ុន Tan Bein វាប៉ះពាល់និង ភូមិអូរទឹកថ្លា មួយដែលពួកគាត់ធ្លាប់រស់នៅតាំងមុនសម័យសង្គ្រាមមក ម្លេះក្រុមហ៊ុននេះបានកាត់ផ្ទៃដីរក្សាទុកសំរាប់ស្តារព្រៃឡើងវិញប្រមាណជា ១.១៩០ហិកតា ផ្ទៃដីតំបន់

ទ្រទាប់ដងអូរ ចំនួន ៣០៧១ហិកតា និងពាក់ពាន់នឹងដីត្រៀមបំរុងទុកបង្កើតសហគមន៍ ព្រៃឈើភូមិថ្មសំល្បៀងចំនួន ៩៣១ហិកតា។ និយាយរួមក្រុមហ៊ុននោះមិនសូវជាប៉ះពាល់ប៉ុន្មានទេ ខ្លះបានដោះស្រាយ និងខ្លះមិនទាន់បានដោះស្រាយ។ ចំពោះក្រុមហ៊ុន តាន បៀន គេបានដាំកៅស៊ូ ប្រមាណជា ៥០០០-៦០០០ហិកតា។ បើពិនិត្យទៅលើគោលការណ៍ មុននឹងធ្វើការវិនិយោគត្រូវចុះបញ្ជីធ្វីរបស់រដ្ឋ (ដែលហៅថា ដីឯកជនរបស់រដ្ឋ) ជាមុនសិននោះទើបជាការល្អ ។

- លោក **កែវ ឆេង** មេឃុំក្រយា : ចំពោះការស្នើសុំដីសម្បទាន ដែលក្រុមហ៊ុនកំពុងអភិវឌ្ឍន៍ប៉ះពាល់ដីស្រែចំការរបស់ប្រជាពលរដ្ឋចំនួនធំក្រុមហ៊ុនគេបានដោះស្រាយរួចអស់ហើយ នៅតែមួយចំនួនតូចជាង១០០គ្រួសារ ដែលពួកគាត់រស់នៅភូមិអូរទឹកថ្លា ឃុំក្រយា។

ចំពោះការដាំដុះរបស់ក្រុមហ៊ុនវិញតាមខ្ញុំ ដឹងខ្លះៗ ក្រុមហ៊ុន តាន បៀន ដាំកៅស៊ូបាន ប្រមាណជា ៤០០០-៥០០០ ហិកតា តាំងពីឆ្នាំ ២០០៧ រហូតមកទល់ឥឡូវនេះចង់គ្រប់ផែនការហើយ។ ឯកការទទួលយកប្រជាពលរដ្ឋក្នុងឃុំចូលបំរើការងារក្រុមហ៊ុនទទួលយកឱ្យតែប្រជាពលរដ្ឋស្ម័គ្រចិត្តធ្វើ ប៉ុន្តែទំលាប់ប្រជាពលរដ្ឋមិនចេះស៊ីឈ្នួលគេទេ ហើយណាមួយកាឱ្យប្រាក់ខែទាបពេកហូបមិនគ្រាន់ ឯអ្នកដែលមកធ្វើការក្នុងក្រុមហ៊ុន តាន បៀន ច្រើនតែមកពីស្ទោង បារាយ និងសន្ទុកខ្លះដែរ។ ប្រាក់ខែកម្មករ មិនតិចជាង៣០ម៉ឺនរៀលទេ ក្នុងមួយខែ គេធ្វើផ្ទះឱ្យកម្មករស្នាក់នៅ ទឹក ភ្លើង ហើយថ្ងៃអនាគត់គេ នឹងសង់សាលារៀន មណ្ឌលសុខភាព។ នៅពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនទាំងបីដែលស្ថិតនៅក្នុងឃុំក្រយាមានដូចជា ក្រុមហ៊ុន Tan Bean , Phueck Va and Ba Ria បានជួយសាលារៀនមួយខ្នងមាន៦បន្ទប់ ប៉ុស្តិ៍សុខភាពមួយកន្លែងនៅ ភូមិសិរីមង្គលចំណាយអស់ទឹកប្រាក់អស់ប្រមាណជា ៦០.០០០ ដុល្លារអាមេរិក។

- លោក **ឡេប សារ៉ន មេភូមិអូរទឹកថ្លា** មានប្រសាសន៍ថា: ការវិនិយោគដាំដំណាំកៅស៊ូនេះ វ៉ានាំកមនូវការអភិវឌ្ឍន៍ប្រទេសជាតិឈានទៅរកការរីកចំរើន កាត់បន្ថយការចំណាកស្រុកទៅកន្លែងឆ្ងាយមិនមានសុវត្ថិភាព ឃ្លាតឆ្ងាយពីប្រពន្ធកូនខាតបង់ប្រាក់ចំណូលក្នុងគ្រួសារ។ ទន្ទឹមនិងនោះដែរក៏មានការប៉ះពាល់មួយចំនួនដែលទៅលើដីស្រែចំការ ដូចជាស្វាយចន្ទី ចំការដំឡូងមី និងដំណាំមួយចំនួនទៀតជាមុខរបរប្រចាំជីវិតរបស់ប្រជាពលរដ្ឋ ដែលពួកគាត់បានកាប់រានធ្វើនៅក្នុងតំបន់វិនិយោគដែលក្រុមហ៊ុនបានស្នើសុំ ហើយក្រុមហ៊ុនបានធ្វើការដោះស្រាយឱ្យប្រជាពលរដ្ឋបានមួយចំនួន ហើយតែនៅសេសសល់មួយចំនួនទៀតដែលនៅមិនទាន់ដោះស្រាយនៅឡើយ គឺនៅផ្ទៃដីចំនួន ៥២៩ហិកតាដែលពាក់ពន្ធ័ នឹងប្រជាពលរដ្ឋប្រហែលពាក់កណ្តាលនៃប្រជាជនសរុប ប្រមាណជាជាង ១០០គ្រួសារទៀត។ ក្នុងរយៈកាលមុន និងក្រោយក្រុមហ៊ុនចូលមកធ្វើការអភិវឌ្ឍន៍នៅក្នុងតំបន់យើងខ្ញុំនោះគឺមានការខុសប្លែកគ្នាច្រើន ពីមុនពួកគាត់ធ្លាប់តែចូលព្រៃ ធ្វើចំការ ដាំដំណាំ និងរកផលអនុផល

Draft

ព្រៃឈើដូចជាជ័រ វល្លិ បេះផ្សិត បេះផ្លែគុយ រកអុស កាប់ឬស្សី ។ល។ តែនៅពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនបានធ្វើការវិនិយោគដាំដើមកៅស៊ូ ហើយបានទទួលយកប្រជាពលរដ្ឋឱ្យមកចូលធ្វើនៅក្នុងក្រុមហ៊ុនជំនួសឱ្យមុខរបររបស់គាត់ ដែលធ្លាប់តែជាកសិករ ឱ្យក្លាយទៅជាកម្មករចំការកៅស៊ូទទួលបានប្រាក់ខែ ប្រជា ២០-៣០ម៉ឺនក្នុង១ខែ ធ្វើឱ្យជីវភាពគ្រួសារមានការផ្លាស់ប្តូរ ។

- លោក **ឌីន** តំណាងឱ្យក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ : មានប្រសាសន៍ថា ពាក់ពន្ធ័និងការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋនៅក្នុងក្រុមហ៊ុន តាន បៀន ត្រូវបានដោះស្រាយឱ្យប្រជាពលរដ្ឋរួចរាល់អស់មួយចំនួនធំហើយ នៅសល់តែ ៥២៩ហិកតាទៀត ដែលស្ថិតនៅគៀកខាងក្រោយភូមិអូរទឹកថ្លា ពុំទាន់បានដោះស្រាយនៅឡើយ ហើយប្រជាពលរដ្ឋក៏នៅតែធ្វើដដែលក្រុមហ៊ុនក៏មិនហាមឃាត់ដែរ ។ ចំណែកឯការដាំដុះវិញក្រុមហ៊ុនបានអនុវត្តដាំដុះរបស់ខ្លួនបានប្រមាណ ៥.៧៥០ ហិកតា ហើយមកដល់បច្ចុប្បន្ននេះ នឹងនៅសល់ចំនួន ១២២០ហិកតាទៀត មិនទាន់បានដាំចប់សព្វគ្រប់ ដោយមូលហេតុខ្វះកូនកៅស៊ូសំរាប់ដាំ ក្រុមហ៊ុននឹងមន្តដាំនៅឆ្នាំក្រោយបន្តព្រោះដីដែលត្រូវដាំបានឈូសឆាយរួចជាស្រេច ។ ចំពោះផ្ទៃដីដាំដុះចំនួន ១២២០ ហិកតានេះ មិនបានបូកបញ្ចូល ចំនួនផ្ទៃដីដែលជាប់ពាក់ពន្ធ័ជាមួយប្រជាពលរដ្ឋចមនួន ៥២៩ ហិកតានោះទេ ។